ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយអគ្គនាយកដ្ឋានពន្ធដារ

# កិច្ចប្រជុំស្តីអំពី
# សរុបលទ្ធផលចំណូលពន្ធប្រចាំខែ មករា ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែមករា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ជួ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខណ្ឌទាំង៩នៅរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តទាំង២៣ទូទាំងប្រទេស។



ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

ឯកឧត្តម **ជួ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជាកិច្ចចាប់ផ្តើមគណៈអធិបតី បានសំដែងអំណរសារទរជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារដែលសំរេចបានប្រចាំខែមករា ឆ្នាំ២០១៤ និងជម្រុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំ ដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានាខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទឲ្យ បានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែងនិងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៤។

ក្នុងខែមករា ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ២៦៥,៦៩៧ លានរៀល (គិតជាដុល្លារប្រមាណ ៦៦.៤លានដុល្លារ)។ បើប្រៀបធៀប

ទៅនឹងខែមករា ដូចគ្នាក្នុងឆ្នាំ២០១៣ មានការកើនឡើងស្មើនិង ១៤.៦% ក្នុងនោះថវិការដ្ឋសំរេច បានចំនួនស្មើនឹង ៦.៧% និងថវិការរដ្ឋបាលថ្នាក់ក្រោមជាតិសំរេចបានចំនួនស្មើនឹង ៤.៦%។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើង ប្រមាណ២៤.៨% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ៣១.១% និង អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ១១% ។

ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២៧.៨% ផ្នែកនីហរ័ណ-អាហរ័ណកើនឡើងប្រមាណ ៤២.៥% ស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៤៩.២% ផ្នែកថ្នាំជក់កើនឡើងប្រមាណ ២០៨.៣% ផ្នែកអាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ១៣៨.៨% ផ្នែកផលិតសម្លៀកបំពាក់ ៣៥% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ២៥.៣% និងផ្នែកដឹកជញ្ជូននិងទេសចរណ៍ ២១.៨% ។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-របាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋាន សាខាពន្ធដារខេត្ត-ខណ្ឌ II-ពិភាក្សាអំពីពន្ធប៉ាតង់និងការដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ III-សេចក្តីជូនដំណឹងស្តីពីបែបបទនៃការដាក់ពាក្យស្នើសុំឈប់ប្រកបអាជីវកម្មជាស្ថាពរនិងជម្រះបញ្ជីសារពើពន្ធ និងIV-បញ្ហាផ្សេងៗ។

ដើម្បីគ្រប់គ្រងចំណូលពន្ធដារឱ្យមានស្ថេរភាពលើវិស័យមួយចំនួន ដែលមានសក្តានុពលចំណូលច្រើន អគ្គនាយកដ្ឋានពន្ធដារមាន គោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៤ ដូចខាងក្រោម៖

- បន្តអនុវត្តនូវគោលការណ៍ និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលបានដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបានសម្រេច កន្លងមក។
- អនុវត្តយ៉ាងម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុការគ្រប់គ្រងឆ្នាំ២០១៤ ដែលបានទទួលការឯកភាពដ៏ខ្ពង់ខ្ពស់ពី**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈលិខិត ៩០០៦ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។







ជាកិច្ចបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលដែលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ ខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសំរេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**អគ្គនាយកដ្ឋានពន្ធដារ**